WWF for a living planet®

WWF មហាតំបន់មេគង្គ
**កម្មវិធីអភិរក្សនៅកម្ពុជា**
ផ្ទះលេខ ២១ ផ្លូវលេខ ៣២២
សង្កាត់បឹងកេងកង១
ប្រអប់សំបុត្រលេខ ២៤៦៧ ភ្នំពេញ

ទូរស័ព្ទ៖ +៨៥៥ ២៣ ២១៨ ០៣៤
ទូរសារ៖ +៨៥៥ ២៣ ២១១ ៩០៩
www.cambodia.panda.org

**សេចក្ដីប្រកាសសារពត៌មាន** **សូមកុំចេញផ្សាយមុនម៉ោង ១២:00នាទីព្រឹក ថ្ងៃទី ១៩ ខែកញ្ញា ២០១១**

# ចំនួនសត្វទន្សោងច្រើនជាងគេនៅលើពិភពលោករស់នៅក្នុងប្រទេសកម្ពុជា កំពុងរងការគំរាមកំហែងពីការបរបាញ់ និងការបាត់បង់ទីជម្រក

ការស្រាវជ្រាវធ្វើឡើងដោយ អង្គការ WWF និងរាជរដ្ឋាភិបាលកម្ពុជា បានប៉ាន់ប្រមាណថាចំនួនសត្វទន្សោងមានចន្លោះពី ២៧០០ ទៅ ៥៧០០ក្បាល រស់នៅក្នុងតំបន់ព្រៃភាគខាងកើតនៃកម្ពុជា។ នេះជាចំនួនសត្វទន្សោងច្រើនជាងគេបំផុតនៅលើពិភពលោក ខណៈពេលដែរការប៉ាន់ប្រមាណចំនួនសត្វទន្សោងនៅលើសាកលលោកមានប្រមាណចន្លោះពី ៥៩០០ ទៅ ១១០០០ក្បាល។ សត្វទន្សោងរស់នៅតំបន់ធម្មជាតិផ្សេងទៀតក្នុងប្រទេសថៃ និងឥណ្ឌូនេស៊ី មានចំនួនតែប៉ុន្មានរយក្បាលប៉ុណ្ណោះ។

សត្វទន្សោង (*Bos javanicus*) ជាសត្វស្ថិតនៅក្នុងប្រភេទសត្វគោសាទិស មានមាឌធំ កម្លាំងខ្លាំង ហើយធន់។ វាទំនងជាបុព្វបុរសនៃពពួកគោសាទិសស្រុកនៅក្នុងតំបន់អាស៊ីអាគ្នេយ៍។ យោងទៅតាមប្រភព អង្គការ IUCN ចំនួនសត្វទន្សោងនៅក្នុងប្រទេសកម្ពុជាបានធ្លាក់ចុះជាង ៩០% ចាប់តាំងពីចុងទសវត្សទី៦០មក។ ចាប់ពីឆ្នាំ ១៩៩៦ សត្វទន្សោងត្រូវបានគេដាក់បញ្ចូលក្នុងបញ្ជីក្រហមរបស់ អង្គការ IUCN ថាជាប្រភេទសត្វកំពុងរងគ្រោះថ្នាក់ជិតផុតពូជជាសាកលដោយផ្អែកលើការធ្លាក់ចុះយ៉ាងខ្លាំងនៃចំនួនសត្វប្រភេទនេះ។

មានតួនាទីជាមន្ត្រីសមភាគីនៃក្រសួងបរិស្ថាន និងជាមន្ត្រីកម្មវិធីស្រាវជ្រាវរបស់ អង្គការ WWF លោក ផាន់ ចាន់ណា ជាអ្នកនិពន្ធម្នាក់នៃរបាយការណ៍ស្រាវជ្រាវចេញផ្សាយក្នុងថ្ងៃនេះ បាននិយាយថា៖ "លទ្ធផលនៃការស្រាវជ្រាវនេះ ជាភស្តុតាងយ៉ាងច្បាស់លាស់បង្ហាញពីសារៈសំខាន់ជាសាកលនៃតំបន់ព្រៃភាគខាងកើតកម្ពុជាសម្រាប់ការអភិរក្សសត្វទន្សោង។"

ក្រៅពីសត្វទន្សោង លទ្ធផលនៃការស្រាវជ្រាវក៏បានបង្ហាញផងដែរពីការកើនឡើងនៃចំនួនថនិកសត្វមានមាឌធំមួយចំនួនទៀតរាប់បញ្ចូលទាំងជ្រូកព្រៃ និងឈ្លូសក្នុងតំបន់នេះ។ សត្វព្រៃទាំងនេះ ជាប្រភេទសត្វជាចំណីដ៏សំខាន់សម្រាប់សត្វខ្លាធំ ហើយសុទ្ធសឹងជាប្រភេទសត្វដែលបានទទួលរងការធ្លាក់ចុះយ៉ាងធ្ងន់ធ្ងរក្នុងប្រទេសកម្ពុជា និងនៅប្រទេសដទៃទៀតក្នុងទ្វីបអាស៊ីក្នុងអំឡុងប៉ុន្មានទសវត្សចុងក្រោយនេះ។

អ្នកនិពន្ធម្នាក់ទៀតនៃរបាយការណ៍ស្រាវជ្រាវ បណ្ឌិត ថូម៉ាស គ្រេហ៍ ជាទីប្រឹក្សាសម្រាប់កម្មវិធីស្រាវជ្រាវជីវចម្រុះនៃអង្គការ WWF បានពន្យល់ថា ទិដ្ឋភាពសំខាន់មួយនៃការស្រាវជ្រាវ គឺការស្វែងយល់អំពីចំនួននៃប្រភេទសត្វជាចំណីរបស់សត្វខ្លាធំ ដូចជា ទន្សោង ជ្រូកព្រៃ និងឈ្លូស ហើយថាវាជាផ្នែកមួយនៃយុទ្ធសាស្ត្រអភិរក្សរបស់រាជរដ្ឋាភិបាលក្នុងការថែរក្សា និងការពារតំបន់ព្រៃភាគខាងកើតសម្រាប់ជាទីជម្រកអាទិភាពនៃសត្វខ្លាធំនៅក្នុងប្រទេសកម្ពុជា។

ដើម្បីជួយឲ្យសត្វខ្លាធំមានចំនួនកើនឡើងវិញ កត្តាដែលចាំបាច់បំផុតមួយគឺការធានានិរន្តរភាពនៃប្រភេទសត្វជាចំណីដូចជាទន្សោងជាដើម។ តំបន់ព្រៃភាគខាងកើតកម្ពុជា ត្រូវបានគេកំណត់ថាជាតំបន់ដ៏ល្អបំផុតមួយក្នុងទ្វីបអាស៊ីសម្រាប់ការស្ដារឡើងវិញនូវចំនួនសត្វខ្លាធំ ដោយផ្អែកលើលក្ខខ័ណ្ឌល្អ ហើយជាទីជម្រកមានទំហំធំ។ មិនតែប៉ុណ្ណោះ កិច្ចខិតខំ

WWF for a living planet®

WWF មហាតំបន់មេគង្គ
**កម្មវិធីអភិរក្សនៅកម្ពុជា**
ផ្ទះលេខ ២១ ផ្លូវលេខ ៣២២
សង្កាត់បឹងកេងកង១
ប្រអប់សំបុត្រលេខ ២៤៦៧ ភ្នំពេញ

ទូរស័ព្ទ៖ +៨៥៥ ២៣ ២១៨ ០៣៤
ទូរសារ៖ +៨៥៥ ២៣ ២១១ ៩០៩
www.cambodia.panda.org



ប្រឹងប្រែងក្នុងការងារគ្រប់គ្រងតំបន់ការពារ និងការពង្រឹងការអនុវត្តន៍ច្បាប់ដែលបានធ្វើឡើងក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងទៅថ្មីៗនេះ សម្រេចបានលទ្ធផលគួរឲ្យកត់សម្គាល់។

កញ្ញា មីហ្សែល អូវិន ជាប្រធានកម្មវិធីអភិរក្សនៃ អង្គការ WWF បាននិយាយថា៖ "ការខិតខំប្រឹងប្រែងខ្ពស់ក្នុងការពង្រឹងការអនុវត្តន៍ច្បាប់របស់ក្រុមល្បាតមានសមាជិកចំនួនប្រមាណ ៦០នាក់ ដែលធ្វើការដើរល្បាតជាប្រចាំទាំងក្នុង និងក្រៅតំបន់ការពារ បានធ្វើឲ្យអ្នកប្រមាញ់សត្វព្រៃមានការខ្លាចរអា។" កញ្ញា បានបន្តថា៖ "ទោះជាយ៉ាងនេះក្តី វាតម្រូវឲ្យមានកិច្ចខិតខំប្រឹងប្រែងច្រើនបន្ថែមទៀតដើម្បីកាត់បន្ថយ និងឈានទៅលុបបំបាត់ការបរបាញ់ខុសច្បាប់នៅក្នុងតំបន់ព្រៃភាគខាងកើតដ៏មានសារៈ សំខាន់នេះ។"

ក្រៅពីការបរបាញ់ តំបន់ព្រៃភាគខាងកើត និងតំបន់ព្រៃដទៃទៀតនៅក្នុងប្រទេសកម្ពុជា បាន និងកំពុងទទួលរងការគំរាមកំហែងពីសម្បទានដីទ្រង់ទ្រាយធំក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងទៅនេះ។ សំពាធពីក្រុមអ្នកវិនិយោគទុនជាតិ និងអន្តរជាតិពាក់ព័ន្ធនឹងសម្បទានកសិកម្ម ក៏ដូចជាផែនការសម្រាប់គម្រោងសាងសង់ហេដ្ឋារចនាសម្ព័ន្ធធំៗ គំរាមកំហែងដល់តំបន់ព្រៃភាគខាងកើតដែលមានតម្លៃជាសាកល។

យោងតាមសំដីរបស់ លោក នីក ខកស៍ ជាប្រធានកម្មវិធីអភិរក្សសត្វព្រៃនៃ អង្គការ WWF បានឲ្យដឹងថាការផ្តល់ដីសម្បទានសេដ្ឋកិច្ចក្នុងតំបន់ការពារ បើទោះបីជាសម្បទាននោះមានទ្រង់ទ្រាយតូចក្តី ក៏វាបង្កឲ្យមានគ្រោះថ្នាក់ និងហេតុប៉ះពាល់អវិជ្ជមាននានា ហើយមិនតែប៉ុណ្ណោះ វាបំផ្លាញតម្លៃនៃកិច្ចខិតខំប្រឹងប្រែងក្នុងការងារអភិរក្សដែលរាជរដ្ឋាភិបាលកម្ពុជា និងដៃគូរបស់ខ្លួន រួមគ្នាសម្រេចបាននៅក្នុងទសវត្សចុងក្រោយនេះ។

លោក បានពន្យល់ថា៖ "វាមានន័យថា តំបន់ការពារនៅក្នុងប្រទេសកម្ពុជា រាប់បញ្ចូលទាំងតំបន់ដែលមានប្រភេទសត្វព្រៃមានតម្លៃជាសាកលរស់នៅ មិនត្រូវបានការពារដោយច្បាប់ដូចដែលគេធ្លាប់បានគិតនោះទេ។"

អង្គការ WWF ទទួចសុំឲ្យរាជរដ្ឋាភិបាលកម្ពុជាជួយពន្លឿនដំណើរការកសាង និងអនុវត្តផែនការចាត់ថ្នាក់តំបន់សម្រាប់តំបន់ការពារដើម្បីការពារតំបន់ដែលមានតម្លៃជីវចម្រុះខ្ពស់ មុននឹងឈានទៅធ្វើការសម្រេចចិត្តថ្មីណាមួយពាក់ព័ន្ធនឹងសម្បទានដី។

លោក នីក ខកស៍ បាននិយាយថា៖ "ដើម្បីជួយខ្លាធំ និងប្រភេទសត្វជាចំណីរបស់វា រាប់បញ្ចូលទាំងសត្វទន្សោងដែលជាប្រភេទសត្វកំពុងរងគ្រោះថ្នាក់ជិតផុតពូជជាសាកល ឲ្យមានចំនួនកើនឡើងវិញនៅក្នុងតំបន់ព្រៃភាគខាងកើត គេចាំបាច់ត្រូវជម្រុញឲ្យការគ្រប់គ្រងតំបន់ការពារមានភាពរឹងមាំ និងប្រសើរជាងមុន ហើយមិនតែប៉ុណ្ណោះថ្នាក់ដឹកនាំជាន់ខ្ពស់នានានៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវផ្តល់ការគាំទ្រ និងមានឆន្ទៈចំពោះការអភិរក្ស។" លោក បានបន្តថា៖ "ប្រសិនបើគ្មានការគ្រប់គ្រងតំបន់ការពារល្អប្រសើរ ហើយគ្មានការគាំទ្រផ្នែកគោលនយោបាយពីថ្នាក់ដឹកនាំកំពូលទេ នោះសមិទ្ធិផលជាច្រើននៃកិច្ចខិតខំប្រឹងប្រែងក្នុងរយៈពេល ១០ឆ្នាំចុងក្រោយនេះ នឹងត្រូវបាត់បង់។ តំបន់ព្រៃភាគខាងកើត គឺជាតំបន់ព្រៃធម្មជាតិមួយដែលនៅសេះសល់ចុងក្រោយក្នុងតំបន់អាស៊ីអាគ្នេយ៍ ហើយប្រសិនបើបាត់បង់ វានឹងបាត់បង់ជារៀងរហូត។"

WWF for a living planet®

WWF មហាតំបន់មេគង្គ
**កម្មវិធីអភិរក្សនៅកម្ពុជា**
ផ្ទះលេខ ២១ ផ្លូវលេខ ៣២២
សង្កាត់បឹងកេងកង១
ប្រអប់សំបុត្រលេខ ២៤៦៧ ភ្នំពេញ

ទូរស័ព្ទ៖ +៨៥៥ ២៣ ២១៨ ០៣៤
ទូរសារ៖ +៨៥៥ ២៣ ២១១ ៩០៩
www.cambodia.panda.org

**សេចក្តីប្រកាសសារពត៌មាន** **សូមកុំចេញផ្សាយមុនម៉ោង ១២:00នាទីព្រឹក ថ្ងៃទី ១៩ ខែកញ្ញា ២០១១**

សម្រាប់ពត៌មានបន្ថែម សូមទាក់ទង:
លោក ទេព អស្នារិទ្ធ
ការិយាល័យសារពត៌មាន និងកិច្ចការសាធារណៈ:
អង្គការ WWF មហាតំបន់មេគង្គ ការិយាល័យកម្មវិធីអភិរក្សនៅកម្ពុជា
ទូរស័ព្ទ: +៨៥៥ (០)២៣ ២១៨ ០៣៤
អ៊ីមែល: asnarith.tep@wwf.panda.org

## ពត៌មានសម្រាប់អ្នកនិពន្ធ៖

- សូមទាញយករបាយការណ៍ស្រាវជ្រាវ និងសាលកប័ត្រពត៌មាន តាមរយៈ៖ http://www.mediafire.com/?crb2lxz0z3age
- រូបថត៖ សូមទាញយករូបភាពសត្វទន្សោង ទីជម្រក ការគំរាមកំហែង និងសកម្មភាពស្រាវជ្រាវតាមរយៈ៖ https://picasaweb.google.com/wwfcambodia/PhotosForBantengRelease1?authkey=Gv1sRgCLHwodGzpInyGg#
- រូបភាពវីដេអូ៖ សូមទាក់ទង Chris Chaplin តាមរយៈ៖ អ៊ីមែល cchaplin@wwf.sg និងលេខទូរស័ព្ទ +៦៥ ៩៨២៦ ៣៨០២
- សម្រាប់ពត៌មានបន្ថែមអំពីប្រវត្តិនៃសត្វទន្សោង សូមទៅកាន់៖

  http://www.iucnredlist.org/apps/redlist/details/2888/0
- អង្គការ WWF និងរាជរដ្ឋាភិបាលកម្ពុជា ធ្វើការគ្រប់គ្រងរួមគ្នានូវតំបន់ការពារចំនួនពីរគឺ ព្រៃការពារមណ្ឌលគិរី និងដែនជម្រកសត្វព្រៃភ្នំព្រេចដែលមានផ្ទៃក្រលាសរុបប្រមាណ ៦០០០ គីឡូម៉ែត្រការ៉េ ដើម្បីអភិរក្សថនិកសត្វប្រភេទជិតផុតពូជដូចជា ខ្លាធំ ដំរីអាស៊ី ក្របីព្រៃ ទន្សោង ខ្ទីង រមាំង ព្រមទាំងសត្វស្លាបប្រភេទជិតផុតពូជជាច្រើនទៀត។ គម្រោងមានទិសដៅថែរក្សា និងការពារបណ្តុំព្រៃទេសភាពដែលនៅសេសសល់ចុងក្រោយនេះឱ្យមានសភាពស្រស់ស្អាត ហើយតភ្ជាប់គ្នា ព្រមទាំងជួយប្រជាជនក្នុងការការពារធនធានសត្វព្រៃ និងលើកកម្ពស់ការចិញ្ចឹមជីវិតរបស់ពួកគេប្រកបដោយនិរន្តរភាព។
- របាយការណ៍ស្រាវជ្រាវមានចំណងជើងថា៖ "ការបង្កើតទិន្នន័យមូលដ្ឋាននៃដង់ស៊ីតេប្រភេទសត្វក្រចកជើងពីរនៅក្នុងព្រៃការពារមណ្ឌលគីរី និងដែនជម្រកសត្វព្រៃភ្នំព្រេច" ត្រូវបានចេញផ្សាយនៅថ្ងៃនេះ ក្នុងគោលបំណងចូលរួមអបអរ ទិវាសត្វខ្លាពិភពលោក ថ្ងៃទី ២៩ ខែកញ្ញា ឆ្នាំ ២០១១។